# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 03-Apr-2019, 15:16
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ:

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ត.ក **សាធារណៈ:/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និង ពេលវេលាបន្ថែម សម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Doreen CHEN

ព្រុំ ផល្លា

Xiaoyang NIE
Marina HAKKOU

**<u>ផ្ញើជូន</u>៖**

**ក្រុមមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

ឌី សុជាតា

Gaëlle BUCHET
Stephanie ERIAN
Khady BÂ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**ពេជ អង្គ**

Marie GUIRAUD

## ផ្នែកទី ១. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ៣៩ នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធានផ្ទៃក្នុង") និង មាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្តអំពីការដាក់ឯកសារ សហមេធាវីការពារក្ដីរបស់ នួន ជា ("មេធាវីការពារក្ដី") ស្នើសុំជាបន្ទាន់ដូចខាងក្រោម៖

(ក) ពេលវេលាបន្ថែម ១៥០ ថ្ងៃ ទៅលើពេលវេលាកំណត់ ៣០ ថ្ងៃ ទៅជាពេលវេលាទាំងអស់មានចំនួន ១៨០ ថ្ងៃវិញ ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ និង

(ខ) ចំនួនទំព័របន្ថែមសម្រាប់សេចក្ដីជូនដំណឹងនេះចំនួន ៧០ ទំព័របន្ថែមលើចំនួនទំព័រដែលបានកំណត់ ៣០ ទំព័រ ទៅជាចំនួនទំព័រទាំងអស់ចំនួន ១០០ ទំព័រជាភាសាអង់គ្លេស។ ហៅថា "សំណើ"។

## ផ្នែកទី២. សាវតា

### I. សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២

២. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះបានប្រកាសជាផ្លូវការនូវសេចក្ដីសង្ខេបសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ទៅលើ នួន ជា និង ខៀវ សំផន ("សាលក្រមសង្ខេប")។ នៅក្នុងសាលក្រមសង្ខេបរបស់ខ្លួន អង្គជំនុំជម្រះបានកត់សម្គាល់ថា "ពេលវេលាកំណត់សម្រាប់ដាក់ជូននូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ នឹងចាប់ផ្ដើមនៅថ្ងៃដំបូងបន្ទាប់ពីទទួលបានសាលក្រមជាលាយលក្ខណ៍អក្សរ ដោយមានហេតុផលពេញលេញ"[1]។

---

[1] "សាលក្រមសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២" ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ("សាលក្រមសង្ខេបសំណុំរឿង០០២/០២")។

៣. នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ អង្គជំនុំជម្រះបានចេញនូវសាលក្រមលាយលក្ខណ៍អក្សរ មានសម្អាងហេតុពេញលេញទៅលើរូប នួន ជា និង ខៀវ សំផន ("សាលក្រម")[2]។ ភាគីទទួលបានសាលក្រមនៅម៉ោង ៨:៣៧ យប់ គឺនៅច្រើនម៉ោងបន្ទាប់ពីការជូនដំណឹងទៅដល់ភាគី។ បើទោះជាសាលក្រមសង្ខេបវាមិនមានភាពជាផ្លូវការក៏ដោយ ក៏សាលក្រមចេញនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ នេះនៅតែដាក់កាលបរិច្ឆេទ ដូចគ្នានឹងសាលក្រមសង្ខេបដែរ គឺថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ២០១៨។

៤. លើសពីនេះទៀតនោះ មេធាវីការពារក្តីកត់សម្គាល់ឃើញថា សាលក្រមសង្ខេបដើមដំបូងដែលបានចែកជូននៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ត្រូវបានសម្គាល់ថា ជាជូនដំណឹងជាមុន ក្រៅផ្លូវការ ត្រូវបានដាក់នៅលើគេហទំព័ររបស់ អវតក ដោយមានការកែតម្រូវដោយមិនមានការសម្គាល់។ វានៅមិនទាន់ច្បាស់នៅឡើយក្នុងពេលនេះថា មានអ្វីខ្លះដែលខុសប្លែកគ្នា។ មេធាវីការពារក្តីមិនបានទទួលដំណឹងពីអង្គជំនុំជម្រះអំពីការកែតម្រូវនេះទេ។

## II. ធនធាននៅក្នុងក្រុមរបស់ នួន ជា

៥. នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៧ នៅភ្លាមៗបន្ទាប់ពីមេធាវីការពារក្តីបានដាក់ជូនសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ដែលត្រូវបានកែតម្រូវ ថវិការសម្រាប់ក្រុមជំនួយផ្នែកច្បាប់របស់ក្រុមមេធាវីការពារក្តីត្រូវបានកាត់បន្ថយនៅកម្រិតទាបដោយមានសម្រាប់តែបុគ្គលិកពេញម៉ោងមួយរូបសម្រាប់បុគ្គលិកជាតិ និង មួយរូបសម្រាប់បុគ្គលិកអន្តរជាតិ។ ការកាត់បន្ថយភ្លាមៗនេះ បានធ្វើឲ្យបញ្ចប់កិច្ចសន្យាទីប្រឹក្សាច្បាប់ពីររូបដែលជាសមាជិកសំខាន់នៅក្នុងសំណុំរឿង ០០២/០២។ ចាប់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៧ ក្រុមមេធាវីការពារក្តីមានសមាជិកតែបីរូប (តាមពិតទៅបួន) ដែលធ្វើការមិនពេញម៉ោង និង សហមេធាវីពីររូប។ ថវិការ ទើបតែមានវិញនៅកម្រិតដូចដែលបានរៀបចំនៅអំឡុងពេលសវនាការ (ដោយមិនរាប់បញ្ចូលនូវថវិការ ដែលផ្តល់ជូនសម្រាប់ការងារលើ

---

[2] E465 "សាលក្រមសំណុំរឿង ០០២/០២" ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ("សាលក្រម")។

ភស្តុតាងដែលដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤) នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដោយសារតែសាលក្រមសង្ខេបបានប្រកាស។

៦. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា ឈ្មោះ Doreen Chen បានលាលែងពីតំណែង[3]ព្រមគ្នាជាមួយនឹងមន្ត្រីច្បាប់កម្រិតទាបមួយរូបទៀត។ នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨ ប្រធានអង្គភាពគាំពារការការពារក្តីបានបញ្ចប់ការងារសហមេធាវីអន្តរជាតិរបស់ នួន ជា គឺ Victor Koppe ដោយមានអនុភាពថយទៅចាប់តាំងពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៨[4]។ ការបញ្ចប់ការងារនេះគឺនៅបន្ទាប់ពីមន្ត្រីច្បាប់ជាន់ខ្ពស់ពីររូបធ្វើការមិនពេញម៉ោង បានលាលែងពីការងារ។ ចាប់តាំងពីចុងខែធ្នូ ឆ្នាំ ២០១៨ រហូតមក ក្រុមមេធាវីការពារក្តីរបស់ នួន ជា មានតែសហមេធាវីជាតិមួយរូបនិង អ្នកវិភាគភស្តុតាងថ្នាក់ខ្ពស់មួយរូប។

៧. នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩ Doreen Chen ត្រូវបានចាត់តាំងជាសហមេធាវីអន្តរជាតិថ្មីសម្រាប់ការពារក្តីលោក នួន ជា[5]។ បន្ទាប់មកសហមេធាវីការពារក្តីបានពន្លឿនដំណើរការជ្រើសរស់បុគ្គលិកសម្រាប់ក្រុម។ នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩ អ្នកវិភាគភស្តុតាងថ្នាក់ខ្ពស់ត្រូវបានចាត់តាំងជាថ្មីឡើងវិញ និងទីប្រឹក្សាចំនួន ៦ ដែលធ្វើការពេញម៉ោង និង មិនពេញម៉ោង ត្រូវបានតែងតាំងសម្រាប់ជំនួយការផ្នែកច្បាប់របស់ក្រុមមេធាវីការពារក្តី។

---

[3] សារអេឡិចត្រូនិចរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់សម្រាប់ក្រុមមេធាវីការពារក្តី នួន ជា, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ **(ឯកសារភ្ជាប់ ១)**។

[4] **E378/8/14** "លិខិតពីប្រធានអង្គភាពគាំពារការការពារក្តី នៃ អវតក ផ្ញើជូនសហមេធាវីអន្តរជាតិរបស់ នួន ជា" ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៨ កថាខណ្ឌ ២។

[5] **E464** "ការចាត់តាំងសហមេធាវីបរទេសថ្មី តំណាងឱ្យលោក នួន ជា នៅក្នុងសំណុំរឿង ០០២/០២" ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៩ ("ការចាត់តាំងមេធាវីបរទេសថ្មី")។

## ផ្នែកទី៣. ច្បាប់ជាធរមាន

## I. សិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌

៨. មាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អវតក ចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និង សាក្សី។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

៩. មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ជាពិសេសស្របទៅនឹងមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (“ICCPR”) ចែងថា៖

> នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរិមា និងស្មើៗគ្នាសមស្របតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ [...] ខ) មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសដោយខ្លួនឯង។[6]

---

[6] មាត្រា ១៤ (៣) របស់ ICCPR ប្រើប្រាស់ភាសាដូចគ្នា៖ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ “ត្រូវមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និង ឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង”។ ការការពារការជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុង ICCPR ក៏ត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា “ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូច

១០. ក្នុងការបកស្រាយមាត្រា ១៤ នៃ ICCPR គណៈកម្មាធិការសិទ្ធិមនុស្ស ("HRC") បានសម្រេចថា "សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តីរបស់ខ្លួន គឺជាធាតុសំខាន់មួយក្នុងការធានានូវភាពយុត្តិធម៌ក្នុងសវនាការ និងក៏បានមកដែរពីគោលករណ៍ស្មើភាពគ្នាក្នុងការតទល់ក្តី"[7] ។

## II. សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ

១១. វិធាន ១០៥ (៣) នៃវិធានផ្ទៃក្នុងចែងថា៖

> ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ អនុលោមតាមលក្ខខណ្ឌនៅក្នុងវាក្យខណ្ឌទី ២ (ក) និង (គ) នៃវិធាននេះ។

---

មានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ"។

[7] *Wright v. Jamaica*, HRC, Comm. No. 349/1989, CCPR/C/45/D/349/1989 (1992 ថ្ងៃទី ១៨ សីហា ឆ្នាំ ១៩៩២ កថាខណ្ឌ ៨.៤ **(ឯកសារភ្ជាប់ ២)**។ សូមមើលផងដែរ *Sawyers and McLean v. Jamaica*, HRC, Comm. Nos. 226/1987 and 256/1987, CCPR/C/41/D/226/1987 ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩១ កថាខណ្ឌ ១៣.៦ **(ឯកសារភ្ជាប់ ៣)**។

១២. វិធាន ១១០ (១) បានចែងថា "វិសាលភាពនៃបណ្តឹងសាទុក្ខត្រូវកម្រិតត្រឹមបញ្ហា ដែលលើកឡើងក្នុងសេចក្តីជូនដំណឹង"។ វិធានមិនបានចែងឲ្យជាក់លាក់ទៅលើឱកាសក្នុងការកែតម្រូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅបន្ទាប់ពីដាក់ជូនរួចហើយនោះទេ។

១៣. អនុលោមតាមវិធាន ១០៧ (៤) "សេចក្តីជូនដំណឹងសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុងវិធាន ១០៥ (៣) ត្រូវប្រើក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងពីសាលក្រមនោះតាមករណីសមស្រប"។

## III. ការបន្ថែមចំនួនទំព័រ

១៤. មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងថា៖

> ឯកសារដាក់នៅអង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូលនៃ អវតក មិនត្រូវលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ៦០ទំព័រជាភាសាខ្មែរ លើកលែងតែមានប្បញ្ញត្តិចែងផ្ទុយពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អវតក សេចក្តីណែនាំអនុវត្តនេះ ឬ បទបញ្ជាចេញដោយ អវតក។

១៥. អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងថា "តាមការស្នើសុំរបស់ភាគីចូលរួម អង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស"។

## IV. ការបន្ថែមពេលវេលា

១៦. អនុលោមតាមវិធាន ៣៩ (៤) អង្គជំនុំជម្រះ "តាមរយៈពាក្យស្នើសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន អាចពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់"។

១៧. HRC ផ្តល់នូវការណែនាំទៅលើអ្វីដែលកំណត់ថា "ពេលវេលាគ្រប់គ្រាន់" សម្រាប់ការរៀបចំក្នុងការការពារក្តីរបស់ជនជាប់ចោទនៅមាត្រា ១៤ នៃ ICCPR៖

> អ្វីដែលចាត់ទុកថា "ពេលវេលាគ្រប់គ្រាន់" គឺអាស្រ័យលើកាលៈទេសៈនៃរឿងក្តីនីមួយៗ។ ប្រសិនបើមេធាវីការពារក្តីយល់ថា ពេលវេលាសម្រាប់ការការពារក្តីមិនគ្រប់គ្រាន់ វាចាំបាច់សម្រាប់ខ្លួនក្នុងការស្នើសុំលើកពេលវេលាសវនាការ។ [...] មានកាតព្វកិច្ចមួយក្នុងការផ្តល់ជូនតាមសំណើសុំពន្យារពេល ជាពិសេសនៅក្នុងករណីដែលជនជាប់ ចោទ ត្រូវបានចោទពីបទល្មើសធ្ងន់ធ្ងរ ដែលពេលវេលាបន្ថែមសម្រាប់ការរៀបចំការការពារក្តីត្រូវការជាចាំបាច់[8]។

## V. កត្តាកំណត់ពីមូលហេតុត្រឹមត្រូវសម្រាប់បន្ថែមទៅនឹងដែនកំណត់

១៨. នៅក្នុងការកំណត់ ពីមូលហេតុសមស្របក្នុងការផ្លាស់ប្តូរនូវការកំណត់នីតិវិធី អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") បានពិចារណានូវកត្តាដូចខាងក្រោម៖ (១) ទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង (២) បញ្ហាថ្មីៗ ដែលត្រូវពិនិត្យ និង (៣) ការចាត់តាំងមេធាវីថ្មី[9]។

១៩. ដូចគ្នានេះដែរ អង្គជំនុំជម្រះនៅក្នុងតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសយូហ្គោស្លាវី ("ICTY") តុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ("ICTR") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") បានទទួលស្គាល់អំពីចំនួនសន្លឹកនៃសាលក្រម[10] ទំហំនៃសំណុំរឿង[11] ឬក៏ភាពស្មុគ

---

[8] HRC, 'General Comment No. 32: មាត្រា ១៤ សិទ្ធិស្មើភាពគ្នាក្នុងតុលាការ និង សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌, CCPR/C/GC/32 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣២ **(ឯកសារភ្ជាប់ ៤)**។

[9] **F6/2** "សេចក្តីសម្រេចលើសំណើសហមេធាវីការពារក្តីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច សុំពេលវេលាបន្ថែមសម្រាប់ដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សេចក្តីសម្រេចលើពេលវេលាបន្ថែមដើម្បីដាក់ជូនបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១" កថាខណ្ឌ ៨ និង ១០។

[10] *Prosecutor v. Karadžić*, MICT-13-55-A, 'សេចក្តីសម្រេចលើសមណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ', ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ("*Karadžić* Decision on Extension"), ទំព័រ ១; **សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូន** ទំព័រ ៨ នៃ ៣១ **ដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២**

ឈ្មោញ និង/ឬ ការពិនិត្យលើបញ្ហាថ្មីៗ[12] ឬ ការខ្វះខាតនៃធនធានសម្រាប់មេធាវីការពារក្តី[13]ថា ជាមូលហេតុសមស្របសម្រាប់ការផ្តល់ជូនចំនួនទំព័របន្ថែម។ តួនាទី ឬ ឋានៈរបស់ជនជាប់ចោទ ក៏ត្រូវបានពិចារណា នៅក្នុងការកំណត់ការផ្លាស់ប្តូរការកំណត់នេះដែរ[14]។

---

*Prosecutor v. Prlić et al.*, IT-04-74-A, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសំណើផ្សេងទៀត', ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ ("*Prlić* Decision on Extension"), ទំព័រ 3; *Prosecutor v. Stanišic and Župljanin*, IT-08-91-A, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៣ ("*Stanišic Decision on Extension*"), ទំព័រ1; *Prosecutor v. Taylor*, SCSL-03-01-A, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ', ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, ទំព័រ 2; *Prosecutor v. Sainović et al., IT-05-87-A*, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ', ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩, ("*Sainović Decision on Extension*"), ទំព័រ. 3; *Prosecutor v. Hadžihasanović and Kubara*, IT-01-47-A, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែម, សំណើសុំទំព័របន្ថែម និង សំណើសុំដាក់ការឆ្លើយតបរួមទៅនឹងបណ្តឹងសាទុក្ខ', ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ កឋាខណ្ឌ ៧។

[11] សេចក្តីសម្រេច *Karadžić* ទំព័រ ១, សេចក្តីសម្រេច *Stanišić* ទំព័រ ១។ *Prosecutor v. Popović et al., IT-05-88-A*, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ', ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ២។ សេចក្តីសម្រេច *Popović* ទំព័រ 2; និង សេចក្តីសម្រេច *Sainović,* ទំព័រ ៣ ។

[12] *Prosecutor v. Bemba Gombo et al.*, ICC-01/05-01/13-2046 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនឯកសារគាំទ្របណ្តឹងសាទុក្ខ' ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ("សេចក្តីសម្រេច *Bemba*") កថាខណ្ឌ ១៨។ *Prosecutor v. Bemba Gombo*, ICC-01/05-01/08-3370 "សេចក្តីសម្រេចលើសំណើ *Bemba* សុំពេលវេលាបន្ថែម ដើម្បីដាក់ជូនឯកសារគាំទ្របណ្តឹងសាទុក្ខ" ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ ("សេចក្តីសម្រេច *Bemba*") កថាខណ្ឌ៦។ *Prosecutor v. Stakić*, IT-97-24-A "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំពេលវេលាបន្ថែម" ថ្ងៃទី ២៦ មេសា ២០០៤, កថាខណ្ឌ ៥។ *Prosecutor v. Karadžić*, MICT-13-55-A, 'សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូននូវសេចក្តីជូនដំណឹង', ថ្ងៃទី ១៥ មិថុនា ២០១៧ ("សេចក្តីសម្រេចលើកទីពីរលើសំណុំសុំពេលវេលាបន្ថែម *Karadžić*"), ទំព័រ៣។ *Prosecutor v. Karadžić*, MICT-13-55-A, 'សេចក្តីសម្រេចលើសំណើសុំពិនិត្យលើអត្ថប្រយោជន៍សម្រាប់បណ្តឹងសាទុក្ខដំណាក់កាល I', ១៥ មិថុនា ២០១៦ ("សេចក្តីសម្រេច *Karadžić*"), កថាខណ្ឌ ២៣។ សេចក្តីសម្រេច *Mladić*។

<u>**ផ្នែកទី ៤. ឧទ្ទិករណ៍**</u>

**I. ការស្នើសុំពេលវេលា និង ចំនួនទំព័របន្ថែម គឺមានប្រយោជន៍ដើម្បីធានាដល់ការគោរពសិទ្ធិ នួន ជា ក្នុងការទទួលបានកាត់សេចក្ដីដោយយុត្តិធម៌**

**ក. សិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ចែងថា នួន ជា ត្រូវតែមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំរឿងក្ដីដោយប្រសិទ្ធភាព**

២០. មេធាវីការពារក្ដីសូមបញ្ជាក់ថា សំណើនេះគួរតែត្រូវបានពិចារណាដោយគិតទៅដល់សិទ្ធិរបស់បុគ្គលក្នុងការមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្ដី។ គោលការណ៍នេះ គឺជាការធានាជាអប្បបរិមាមួយនៃសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ ដូចដែលមានចែងនៅមាត្រា ១៤ របស់ ICCPR និងទទួលស្គាល់ដោយ អវតក និង តុលាការអន្តរជាតិផ្សេងទៀត និង ដោយប្រទេសកម្ពុជាដូចមានក្នុងរដ្ឋធម្មនុញ្ញ។

២១. ជាពិសេសនៅក្នុងតុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) បានសម្រេចជាដដែលៗថា បទប្បញ្ញត្តិ ស្ដីអំពីសិទ្ធិមនុស្ស ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ផង គឺ“មានបំណងធានានូវសិទ្ធិដែលអនុវត្ត និងមានប្រសិទ្ធភាព តែមិនមែនសិទ្ធិដែលមាន

---

[13] សេចក្ដីសម្រេចលើកទីពីរ *Karadžić* លើសំណើសំពន្យារពេល ទំព័រ ៣។ “រំលឹកឡើងវិញពីសេចក្ដីសម្រេចទៅលើសំណើសុំពិនិត្យ សម្រាប់បណ្ដឹងសាទុក្ខដំណាក់កាលទី ១ ដែលរកឃើញថា *Karadžić* មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការរៀបចំបណ្ដឹងសាទុក្ខរបស់ខ្លួន”, កថាខណ្ឌ ២៣ “ដោយមិនបាច់និយាយទៅដល់ភាពស្មុគ្រស្មាញនៃសំណុំរឿង ដែលមិនគ្រាន់តែសម្រាប់ធានាផ្ដល់ជូនពេលវេលាបន្ថែមសម្រាប់ក្រុមការពារក្ដីរបស់គាត់ សម្រាប់ការរៀបចំគ្រប់គ្រាន់ទៅលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។ ទំហំ និងស្ថានភាពដែលមិនអាចប៉ាន់ស្មានបាននៃសំណុំរឿង ក៏មានន័យថា ក្រុមមេធាវីការពារក្ដីរបស់ *Karadžić* ក៏ត្រូវការសមាជិកថែមទៀត ច្រើនជាងការផ្ដល់ឲ្យមេធាវីការពារក្ដីផ្សេងទៀតដើម្បីធ្វើការលើបណ្ដឹងសាទុក្ខនៅ ICTY, ICTR ឬ MICT”។

កដកថស

[14] សេចក្ដីសម្រេច *Sainović,* ទំព័រ ៣ និង សេចក្ដីសម្រេច *Karadžić* ទំព័រ ១។

គ្រាន់តែជាទ្រឹស្តី និង ស្រមើស្រម៉ៃនោះទេ”[15]។ ECtHR បន្ថែមទៀតថា ដើម្បីកំណត់ថា ពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ សម្រាប់បុគ្គលមួយក្នុងការរៀបចំការការពារក្តី នោះ អង្គជំនុំជម្រះត្រូវតែគិតថាតើ ពេលវេលា និង មធ្យោបាយដែលត្រូវបានស្នើគឺជាបទប្បញ្ញត្តិ គ្រប់គ្រាន់ដែលអនុវត្ត និងមានប្រសិទ្ធិភាពក្នុងការការពារក្តី។

២២. ដោយស្របទៅនឹងគោលជំហររបស់ ECtHR អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បានផ្តល់ជូននូវពេលវេលា និង ចំនួនទំព័របន្ថែមក្នុងការដាក់ជូននូវបណ្តឹងសាទុក្ខរបស់ខ្លួន ដើម្បីធានាឱ្យជនជាប់ចោទទទួលបាន “ពេលវេលា និង មធ្យោបាយគ្រប់គ្រាន់”[16]។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តី *Abu Garda* ចៅក្រមមួយនៃអង្គបុរេជំនុំជម្រះនៃ ICC បានពិចារណាទៅដល់សិទ្ធិរបស់ជនជាប់ចោទ “ក្នុងការមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀប ចំដោយប្រសិទ្ធភាពនូវការការពារក្តីរបស់ខ្លួន” នៅពេលបង្កើតប្រតិទិនសម្រាប់សំណុំ រឿង[17]។

## ខ. សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជាផ្នែកមួយដ៏សំខាន់នៃការរៀបចំការពារក្តី របស់ នួន ជា

២៣. នៅចំពោះមុខ អវតក ក្នុងវិធាន ១០៥ (៣) និង ១១០ (១) តម្រូវឱ្យភាគីស្នើសុំដើម្បីធ្វើ បណ្តឹងសាទុក្ខដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលមានមូលដ្ឋានជាក់លាក់

---

[15] *Artico v. Italy*, ECtHR, App. No. 6694/74 “សាលក្រម” ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៨០ កថាខណ្ឌ ៣៣ (បញ្ជាក់បន្ថែម) **(ឯកសារភ្ជាប់ ៥)**។

[16] **F9** “សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប” ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៤ (“សេចក្តីសម្រេចលើកទីពីរលើពេលវេលា និង ចំនួនទំព័រកំណត់”) កថាខណ្ឌ ១៣។

[17] *Prosecutor v. Abu Garda*, ICC-02/05-02/09-18 “សេចក្តីសម្រេចលើកាលវិភាគសវនាការលើបញ្ហាទាក់ទងនឹងការដាក់បង្ហាញរវាងភាគី” ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ១៤។

ដែលខ្លួនប្ដឹងទាស់។ បន្ទាប់មកទៀត ដើមបណ្ដឹងត្រូវតែដាក់ជូនបណ្ដឹងសាទុក្ខដែលពន្យល់ពីអំណះអំណាង និង ឯកសារយោងនានា ដែលគាំទ្រដល់មូលដ្ឋាននីមួយៗ។ បទដ្ឋានការងារនៅ អវតក មិនផ្ដល់នូវលក្ខណៈណាមួយសម្រាប់ភាគីធ្វើការកែតម្រូវលើមូលដ្ឋាននៃបណ្ដឹងសាទុក្ខ នៅពេលដែលសេចក្ដីជូនដំណឹងត្រូវបានដាក់ជូន ដោយកម្រិតត្រឹមតែវិសាលភាពដែលបានលើកឡើងតែប៉ុណ្ណោះ។

២៤. តែផ្ទុយទៅវិញ វិធានរបស់ ICTY និង ICTR អនុញ្ញាតឲ្យភាគីអាចផ្លាស់ប្ដូរមូលដ្ឋាននៃបណ្ដឹងសាទុក្ខរបស់ខ្លួនបាន[18]។ ចំពោះការអនុវត្ត ការផ្លាស់ប្ដូរនេះត្រូវបានអនុញ្ញាតជាញឹកញាប់[19]។ វិធាននៅ ICC ផ្ដល់នូវការលើកលែងលើសពីនេះ ដោយភាគីគ្រាន់តែបញ្ជាក់នៅក្នុងសេចក្ដីជូនដំណឹងអំពីឈ្មោះ និង លេខសំណុំរឿង កាលបរិច្ឆេទនៃសេចក្ដីសម្រេច ហើយបញ្ជាក់ថា តើបណ្ដឹងសាទុក្ខជំទាស់ទៅនឹងសេចក្ដីសម្រេចទាំងមូល ឬក៏ដោយផ្នែកខ្លះ[20]។ មូលដ្ឋាននៃបណ្ដឹងសាទុក្ខត្រូវរៀបរាប់នៅក្នុងបណ្ដឹងសាទុក្ខវិញ ដែលត្រូវដាក់ជូន

---

[18] វិធាន ១០៨ នៃវិធាននីតិវិធី និង ភស្តុតាងរបស់ ICTY ។ វិធាន ១០៨ នៃវិធាននីតិវិធី និង ភស្តុតាងរបស់ ICTR ប្រើប្រាស់ភាសាដូចគ្នា។

[19] *Prosecutor v. Šainović* et al., IT-05-87-A "សេចក្ដីសម្រេចលើសំណើទីពីររបស់ Dragoljub Ojdanić សុំកែតម្រូវបណ្ដឹងសាទុក្ខ" ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៩។ *Prosecutor v. Šainović* et al., IT-05-87-A "សេចក្ដីសម្រេចលើសំណើរបស់ Nebojša Pavković សុំកែតម្រូវបណ្ដឹងសាទុក្ខ" ថ្ងៃទី ៩ កញ្ញា ២០០៩។ *Prosecutor v. Nahimana* et al., ICTR-99-52-A "សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្តសំណើផ្ទាល់មាត់ដើម្បីមិនឲ្យពិចារណាលើអំណះអំណាងរបស់មេធាវីការពារក្ដីរបស់ Barayagwiza នៅក្នុងសវនាការលើបណ្ដឹងសាទុក្ខ នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧" ថ្ងៃទី៥ ខែ មីនា ឆ្នាំ ២០០៧។

[20] វិធាន ៥៧ នៃ វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា "ដើមបណ្ដឹងត្រូវដាក់ជូននូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខដែលត្រូវរៀបរាប់ថា៖ (ក) ឈ្មោះ និង លេខសំណុំរឿង (ខ) កាលបរិច្ឆេទនៃសេចក្ដីសម្រេចចោទប្រកាន់ ឬក៏លើកលែងការចោទប្រកាន់ ការដាក់ទោស ឬក៏សំណង (គ) ថាតើបណ្ដឹងសាទុក្ខគឺជំទាស់ដោយផ្ទាល់ទៅលើសេចក្ដីសម្រេចទាំងមូល ឬក៏ដោយផ្នែក (ឃ) សំណើសុំ"។ សុំមើលផងដែរ *Prosecutor v. Bemba Gombo*, ICC-01/05-

នៅក្នុងរយៈពេល ៩០ ថ្ងៃ នៅបន្ទាប់ពីទទួលបាននូវសេចក្តីសម្រេច ហើយថែមទាំងអាចកែតម្រូវបាននៅបន្ទាប់ពីបណ្តឹងនេះត្រូវបានដាក់ជូន[21]។

២៥. លើសពីនេះទៀត នៅតុលាការអន្តរជាតិផ្សេងទៀត ផ្តល់ជូនដល់ភាគីនូវឱកាសកែតម្រូវមូលដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួន ហើយភាគីថែមទាំងត្រូវបានផ្តល់ជូនជាញឹកញាប់នូវពេលវេលាបន្ថែមក្នុងការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខផងដែរ ដោយការធ្វើដូចនេះអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ភាគីក្នុងការរៀបចំដោយប្រសិទ្ធភាព។ សេចក្តីសម្រេចបែបនេះត្រូវបានពិភាក្សាខាងក្រោមនៅក្នុងសំណើនេះ។

២៦. ដោយពិចារណាទៅលើតម្រូវការ នៅក្នុងសំណុំរឿងនេះ ក្នុងការផ្តល់ជូនជាក់លាក់នូវមូលដ្ឋានបណ្តឹងសាទុក្ខ និងពុំមានឱកាសមួយដ៏ពិតប្រាកដ ក្នុងការកែតម្រូវមូលដ្ឋាននៅបន្ទាប់ពីបានដាក់ជូន ហេតុនេះហើយសេចក្តីជូនដំណឹងរបស់ នួន ជា នឹងជាផែនទីនាំផ្លូវសម្រាប់ដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខរបស់ខ្លួន[22]។ អាស្រ័យហេតុនេះហើយ វាគឺជាតួនាទីរបស់មេធាវីការពារក្តីក្នុងការកំណត់នូវរាល់ផ្នែកច្បាប់ដែលពាក់ព័ន្ធ អង្គហេតុ និង បញ្ហានីតិវិធីដែលកើតមាននៅក្នុងសាលក្រម និង នៅក្នុងពេលសវនាការ ដើម្បីរៀបចំនូវសេចក្តីជូនដំណឹងឱ្យបានទូលំទូលាយ និង ត្រឹមត្រូវ។ ការប្រញាប់ប្រញាល់ ភាពមិនពេញលេញ ឬ សេចក្តីជូនដំណឹងមិនច្បាស់លាស់ ដោយសារតែចំនួនទំព័រ និង ពេលវេលាកំណត់ នឹងអាច

---

01/08-3348 "សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជំទាស់ទៅនឹងសាលក្រមដោយអនុលោមតាមមាត្រា ៧៤, ICC-01/05-01/08-3343" ថ្ងៃទី ៤ មិថុនា ២០១៦។

[21] វិធាន ៥៨ និង ៦១ នៃវិធានរបស់ ICC។

[22] សារសំខាន់នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខត្រូវបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចលើកទីពីរ *Karadžić* នៅទំព័រ ៣ "ការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ កំណត់នូវការងារនៅក្នុងបណ្តឹងសាទុក្ខត្រូវបានពិចារណា និងថា ជាប្រយោជន៍យុត្តិធម៌ក្នុងការធានាថា *Karadžić* មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសេចក្តីជូនដំណឹងដោយអនុលោមតាមបទប្បញ្ញត្តិ" *មើលផងដែរ* *Mladić* សេចក្តីសម្រេចលើសំណើសុំពន្យារពេល ទំព័រ ២ "ដើម្បីជាផលប្រយោជន៍យុត្តិធម៌ក្នុងការធានាថា ភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការជូនដំណឹងដោយមានប្រសិទ្ធភាពដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន"។

ដកចេញដោយមានប្រសិទ្ធភាពនូវការការពារក្ដីដោយមានប្រសិទ្ធភាព ដោយសារតែ នួន ជា ត្រូវបានកំណត់ដោយវិសាលភាពនៃសេចក្ដីជូនដំណឹងនៅក្នុងដំណើរការ។ អាស្រ័យហេតុនេះហើយ សេចក្ដីជូនដំណឹង គឺជាផ្នែកសំខាន់នៃការរៀបចំការការពារក្ដីដ៏មានប្រសិទ្ធភាពរបស់ នួន ជា។

២៧. តាមបទដ្ឋានជាអប្បបរិមាក្នុងការធានាដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នួន ជា ចាំបាច់ត្រូវមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន។

២៨. លើសពីនេះទៀតនោះ ដើម្បីផលប្រយោជន៍យុត្តិធម៌ មេធាវីការពារក្ដីគួរត្រូវបានផ្ដល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំសេចក្ដីជូនដំណឹងឲ្យមានប្រសិទ្ធភាព។ សំណុំរឿងនេះមិនមែនគ្រាន់ជាសំណុំរឿងចុងក្រោយសម្រាប់ នួន ជា នៅចំពោះមុខ អវតក និង ទំនងជាសំណុំរឿងចុងក្រោយនៅ អវតក នោះទេ ក៏ប៉ុន្ដែវាជាដំណាក់កាលចុងក្រោយនៃនីតិវិធីប្រឆាំងនឹងសមាជិកនៅរស់រានជីវិត ដែលមានតួនាទី និង ឋានៈខ្ពស់នៃបក្សកុម្មុយនិស្ដកម្ពុជា។ ជាសង្ខេបមក វាប្រហែលជាឱកាសចុងក្រោយសម្រាប់ អវតក ដើម្បីជួយស្វែងរកការពិតនូវព្រឹត្តិការណ៍ដែលបានកើតឡើងទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ (“កប”)។ នៅក្នុងបរិបទនេះ ការមានសេចក្ដីជូនដំណឹងទូលំទូលាយ ដែលរៀបរាប់យ៉ាងច្បាស់អំពីមូលដ្ឋាននៃបណ្ដឹងសាទុក្ខ នឹង មិនគ្រាន់តែគោរពដល់សិទ្ធិ នួន ជា ក្នុងការទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងសម្រួលដល់ការប្រព្រឹត្តដោយត្រឹមត្រូវនៃដំណើរការបណ្ដឹងសាទុក្ខជារួមផងដែរ[23]។

---

[23] *Prosecutor v. Bosco Ntaganda*, ICC-01/04-02/06-2272 “សេចក្ដីសម្រេចលើសេចក្ដីណែនាំបន្ថែមទៅលើបណ្ដឹងសាទុក្ខ” ថ្ងៃទី ១៣ មេសា ២០១៨ កថាខណ្ឌ ១០ (“កត់សម្គាល់អំពីផលប្រយោជន៍របស់ភាគី អ្នកចូលរួម និង អង្គជំនុំជម្រះ ដើម្បីទទួលបានសេចក្ដីសន្និដ្ឋានបញ្ចប់មួយដែលមានន័យទូលំទូលាយ និង ត្រឹមត្រូវបំផុតតាមដែលអាចធ្វើបាន ចៅក្រមភាគច្រើនទទួលស្គាល់ថា វាជាការត្រឹមត្រូវនៅក្នុងកាលៈទេសៈនេះដើម្បីផ្ដល់ជូននូវទំព័របន្ថែមតាមសំណើ”)។

### គ. ការពន្លឿនមិនត្រូវឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃការកាត់សេចក្តីនោះទេ

២៩. ជាងនេះទៅទៀត មេធាវីការពារក្តីសូមរំលឹកដល់អង្គជំនុំជម្រះថា បើទោះជាការពន្លឿននីតិវិធីគឺជាជម្រើសពាក់ព័ន្ធមួយនៅក្នុងដំណើរការក្តីក៏ដោយ ក៏ត្រូវតែមិនឲ្យប៉ះពាល់ដល់ដំណើរការយុត្តិធម៌នោះទេ។

៣០. ដូចដែល ECtHR កត់សម្គាល់លើបញ្ហានេះនៅក្នុងសំណុំរឿង *Papadakis v. Former Yugoslav Republic of Macedonia* ទាក់ទងទៅនឹងលទ្ធភាពនៃការពន្យារពេលនីតិវិធី "មិនអាចធ្វើឲ្យត្រឹមត្រូវនៃដែនកំណត់នៃសិទ្ធិការពារក្តីរបស់ដើមបណ្តឹងនោះទេ" ពិព្រោះ "សិទ្ធិទទួលបានភាពត្រឹមត្រូវនៅក្នុងវិស័យយុត្តិធម៌ គឺចាំបាច់ត្រូវតែមាននៅក្នុងសង្គមប្រជាធិបតេយ្យ ហើយដែលមិនអាចបោះបង់ចោលដើម្បីពន្លឿននីតិវិធីនោះទេ"[24]។

៣១. ដូចគ្នានេះដែរនៅក្នុងសំណុំរឿង *OAO Neftyanaya Kompaniya Yukos v. Russia*, ECtHR បានសម្រេចថា ទាក់ទងនឹងពេលវេលាដែលបែងចែកដល់មេធាវីការពារក្តីដើម្បីអានសំណុំរឿងនៅមុនពេលសវនាការថា៖

> បើទោះជាវា [...] មានសារសំខាន់នៅក្នុងការដំណើរការនីតិវិធីនៅក្នុងល្បឿនមួយល្អ តែវាមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធីនីតិវិធីនៃភាគីណាមួយនោះទេ ជាពិសេសនៅក្នុងពេលវេលាខ្លីនៃដំណើរការនីតិវិធីនៃសំណុំរឿងធំ និង ស្មុគស្មាញបែបនេះ[25]។

## II. សំណើសុំពេលវេលា និងចំនួនទំព័របន្ថែម គឺត្រឹមត្រូវ និងសមហេតុផល

### ក. សាលក្រម និង សណុំរឿងមានភាពស្មុគស្មាញ និង ទូលំទូលាយ

---

[24] *Papadakis v. Former Yugoslav Republic of Macedonia*, ECtHR, App. No. 50254/07 "សាលក្រម" ថ្ងៃទី ២៦ ឧសភា ២០១៣ កថាខណ្ឌ ៩៤ (មើល **E409.1.2**)។

[25] *OAO Neftyanaya Kompaniya Yukos v. Russia*, ECtHR, App. No. 14902/04 "សាលក្រម" ថ្ងៃទី ២០ កញ្ញា ២០១១ កថាខណ្ឌ ៥៤០ (**ឯកសារភ្ជាប់ ៦**)។

៣២. សាលក្រមនៅក្នុងសំណុំរឿងនេះ គឺសាលក្រមមួយនៅក្នុងចំណោមសាលក្រមវែងបំផុតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយភាសាអង់គ្លេសមានចំនួនទំព័ររហូតដល់ ២ ២៥៩, ជើងទំព័រចំនួន ១៤ ៤៤៦។ ចំនួនឯកសារដែលគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាមទារឱ្យមានការត្រួតពិនិត្យហ្មត់ចត់ដើម្បីកំណត់នូវកំហុសអង្គហេតុនានា។ សេចក្តីសន្និដ្ឋានភាគច្រើនក៏ពាក់ព័ន្ធទៅនឹងកំហុសនីតិវិធី ដែលអាចកើតមាននៅក្នុងអំឡុងពេលសវនាការដែលមានភាពស្មុគ្រស្មាញ និងប្រើរយៈពេលយូរ។

៣៣. តាមទំហំរបស់សាលក្រម និង ពេលវេលាកំណត់រយៈពេល៣០ថ្ងៃ សម្រាប់ដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ធ្វើឱ្យមេធាវីការពារក្តីជួបនូវ “គ្រោះថ្នាក់ដែលមិនអាចគេចរួច (catch 22)” មានន័យថាជាធ្វេគ្រោះ។ វាមានការលំបាកក្នុងការកំណត់ឱ្យបានពិតប្រាកដពីសេចក្តីត្រូវការរបស់ នួន ជា សម្រាប់សេចក្តីជូនដំណឹង ដោយមិនបានអាន និង វិភាគសាលក្រម។ ដោយសារតែទំហំរបស់សាលក្រម មេធាវីការពារក្តីប៉ាន់ស្មានថា ខ្លួនយ៉ាងហោចណាស់ក៏ប្រើរយៈពេល១៥ថ្ងៃ (គឺ ៣ សប្តាហ៍) សម្រាប់គ្រាន់តែអានអត្ថបទគោល។ ការប៉ាន់ស្មាននេះដោយផ្អែកទៅលើអត្រាអានចំនួន ២០ ទំព័រ ក្នុងរយៈពេលមួយម៉ោង ដែលស្មើនឹង ១៥០ ទំព័រ សម្រាប់រយៈពេលថ្ងៃធ្វើការចំនួនប្រាំបីម៉ោង។ ការប៉ាន់ស្មានេះដោយមិនរាប់បញ្ចូលពេលវេលាដែលត្រូវការសម្រាប់ការវិភាគបឋម ដោយផ្ទៀងផ្ទាត់ទៅលើឯកសារយោងនៅក្នុងជើងទំព័រ ឧបសម្ព័ន្ធ សេចក្តីសន្និដ្ឋានរបស់ភាគី ដីកាដំណោះស្រាយ ដោយមិនគិតផងដែរអំពីការបង្កើត និង ធ្វើពង្រៀងមូលដ្ឋាននៃបណ្តឹងសាទុក្ខ។ នេះមិនទាន់គិតដល់ភាពយឺតយ៉ាវរបស់ នួន ជា នៅក្នុងការអាន និង ទាក់ទងគ្នា ដោយសារតែវ័យចាស់របស់គាត់ និង ដោយសារតែបញ្ហាភ្នែក និងរាងកាយរបស់គាត់ដែលកាន់តែថយចុះ និង ការចងចាំរបស់គាត់ដូចដែលអង្គជំនុំជម្រះបានដឹងអំពីការងារកំពុងតែបន្តរបស់តុលាការ ក្នុងការវាយតម្លៃអំពីសម្បទារបស់ នួន ជា ដើម្បីចូលរួមក្នុងសវនាការ ហើយតែងទទួលបានការព្យាបាលជាញឹកញាប់។ ដោយសារតែការប្រឈមនេះហើយ មេធាវីការពារក្តីត្រូវការពេលវេលា កាន់តែច្រើនកាន់តែល្អ ដើម្បីធ្វើការជាមួយ នួន ជា។

៣៤. អាស្រ័យហេតុនេះហើយ បើទោះជានៅក្នុងដំណាក់កាលដំបូងនេះវាមិនអាចកំណត់ឱ្យបាន ប្រាកដអំពីសេចក្តីត្រូវការរបស់ នួន ជា សម្រាប់សេចក្តីជូនដំណឹងនេះ ក៏មេធាវីការពារក្តី អាចបញ្ជាក់ថា ចំនួន ពេល ៣០ ថ្ងៃ គឺមិនគ្រប់គ្រាន់ទេ សម្រាប់មេធាវីការពារក្តីក្នុងការ កំណត់ទៅលើកំហុសអង្គច្បាប់ អង្គហេតុ និង កំហុសនីតិវិធីដែលអាចមាននៅក្នុងសាល ក្រម។ ដូចនេះពេលវេលាបន្ថែម គឺចាំបាច់ណាស់សម្រាប់មេធាវីការពារក្តីអាចរៀបចំ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលត្រូវបានផ្តោតយកចិត្តទុកដាក់ និង ពីចារណាឱ្យ បានហ្មត់ចត់ និងបន្ទាប់មកត្រូវមានការប្រឹក្សាយោបល់គ្រប់គ្រាន់ជាមួយ នួន ជា។

៣៥. ជាងនេះទៅទៀតនោះ ក្នុងពេលនេះមេធាវីការពារក្តីមិនអាចកំណត់ពេលវេលា (ឬ ចំនួន ទំព័រ) ដែលអាចគ្រប់គ្រាន់នៅឡើយទេ បើទោះជាខ្លួនបានព្យាយាមអស់ហើយនៅក្នុងសំណើ នេះ។ អាស្រ័យហេតុនេះហើយ វាចាំបាច់ណាស់សម្រាប់មេធាវីការពារក្តីស្នើសុំចំនួនពេល វេលា និង ទំព័របន្ថែមសម្រាប់សេចក្តីជូនដំណឹង។ សម្រាប់ហេតុផលនេះហើយ មេធាវីការ ពារក្តីកំណត់ថា នេះជាសំណើទីមួយរបស់ នួន ជា សម្រាប់បញ្ហានេះ។

៣៦. មេធាវីការពារក្តីចាត់ទុកថានេះជាសំណើបន្ទាន់ ដោយសារតែពេលវេលាកំណត់សម្រាប់ ពេលបច្ចុប្បន្ននេះសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹង និងពេលវេលាដែលរំពឹងទុក សម្រាប់ការអាន និង ចាប់ផ្តើមវិភាគសាលក្រម។ អង្គជំនុំជម្រះបានពន្លឿនការជូនដំណឹង របស់ខ្លួន យ៉ាងហោចណាស់ផ្នែកសេចក្តីសម្រេចរបស់ខ្លួន ដោយសារតែសំណើនេះសំខាន់ និង ត្រូវបានកោតសរសើរ ដើម្បីធានាដល់ការប្រើប្រាស់ពេលវេលា និង មធ្យោបាយគ្រប់ គ្រាន់ ដែលផ្តល់ជូន នួន ជា ក្នុងការរៀបចំការការពារក្តីរបស់ខ្លួន។ ជាពិសេស វាអាចការ ពារមេធាវីការពារក្តីពីការប្រើប្រាស់ពេលវេលា និង ធនធាន ឥតប្រយោជន៍ ដោយព្យាយាម បំពេញការងារមិនល្អក្នុងការរៀបចំសេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ ៣០ ថ្ងៃនេះ។

## ១. ប្រៀបធៀបជាមួយសំណុំរឿង ០០២/០១

៣៧. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានទទួលស្គាល់ពីចំនួនទំព័រ នៃសាលក្រម (មានចំនួន ៦២៣ ទំព័រ ភាសាអង់គ្លេស)[26] និង តម្រូវការក្នុងពិភាក្សាដោយហ្មត់ចត់នៅក្នុងក្រុម និង ជាមួយកូនក្តី ថា ជាកត្តាសំខាន់ក្នុងការកំណត់ពេលវេលា សម្រាប់សេចក្តីជូនដំណឹង និង សម្រាប់បណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះបានផ្តល់ជូនមេធាវីការពារក្តីចំនួន ២៣ ថ្ងៃ បន្ថែមទៀត ដើម្បីដាក់ជូននូវសេចក្តីជូនដំណឹងរបស់ខ្លួន[27] គិតសរុបទាំងអស់ចំនួន ៥៣ ថ្ងៃ។ ដោយមានភាពប្រហាក់ប្រហែលគ្នាទៅលើ "ទំហំ និង ភាពស្មុគ្រស្មាញនៃសំណុំរឿង និង សាលក្រម"[28] អង្គជំនុំជម្រះបន្ទាប់មកបានបន្ថែមពេលវេលា និង ចំនួនទំព័រដល់មេធាវីការពារក្តីក្នុងការដាក់ជូននូវបណ្តឹងសាទុក្ខរបស់ខ្លួន[29] ដើម្បីអនុញ្ញាតឲ្យ "មានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី"[30]។

៣៨. ពិសេសជាងនេះទៅទៀតនោះ សាលក្រមនៅក្នុងសំណុំរឿង ០០២/០២ វែងជាងសាលក្រមក្នុងសំណុំរឿង ០០២/០១ ជិតបួនដង។ នេះជាសំណុំរឿងថិតនៅក្នុងសំណុំរឿងដ៏ធំបំផុង និង ស្មុគ្រស្មាញជាងគេ នៅក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ឯកសារនៅក្នុងសំណុំរឿងរាប់បញ្ចូលទាំងឯកសារមកពីសំណុំរឿង ០០១, ០០២/០១[31], ០០៣, ០០៤,

---

[26] សូមមើល "សាលក្រម សំណុំរឿង ០០២/០១" ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

[27] **F3/3** "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ" ២៩ សីហា ២០១៤ ("សំណើលើកទីមួយលើការកំណត់ពេលវេលា និង ទំព័រ នៅក្នុងសំណុំរឿង ០០២/០១") កថាខណ្ឌ ៩។

[28] **F3/3** "សំណើលើកទីមួយលើការកំណត់ពេលវេលា និង ទំព័រ នៅក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១០។

[29] **F9** "សេចក្តីសម្រេចលើកទីពីរ លើការកំណត់ពេលវេលា និង ចំនួនទំព័រក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១៣។ **F13/2** "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប" ១១ ធ្នូ ២០១៤ កថាខណ្ឌ ១៥ ដល់ ១៦។

[30] **F3/3** "សំណើលើកទីមួយលើការកំណត់ពេលវេលា និង ទំព័រ នៅក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១០។

[31] ចំពោះភាពទូទៅនៃភស្តុតាងរវាងសំណុំរឿង ០០២/០១ និង ០០២/០២ សូមមើល "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី

០០៤/០១ និង ០០៤/០២។ ជាពិសេសភស្តុតាងថ្មីៗ ជាច្រើនដូចព្យុះស៊ូណាមី ដែលជាកំណត់ហេតុស្តាប់ចម្លើយ ពីសំណុំរឿង ០០៣, ០០៤, ០០៤/០១ និង ០០៤/០២ ដែលដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ អំឡុងពេលដែលសវនាការមិនទាន់ចប់ ហើយមានពេលខ្លះអ្នកស៊ើបអង្កេតបានទៅសម្ភាសសាក្សីជាថ្មីម្តងទៀត។

៣៩. អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានទទួលស្គាល់ថា ខ្លួន"បានប៉ាន់ប្រមានខុសនូវពេលវេលាចាំបាច់ក្នុងការពិនិត្យមើលភស្តុតាង ដែលមានចំនួនច្រើនក្នុងសំណុំរឿងស្មុគស្មាញនេះ" ដើម្បីជាយុត្តិកម្មក្នុងការចេញសាលក្រមរបស់ខ្លួន[32]។ តាមពិតទៅរយៈពេល និង មធ្យោបាយដែលត្រូវការក្នុងការចេញសាលក្រម និងពេលវេលាត្រូវការត្រួតពិនិត្យ គឺជាការចង្អុលបង្ហាញដោយត្រឹមត្រូវដោយគិតទៅលើចំនួន និង ភាពស្មុគស្មាញនៃបញ្ហាដែលពាក់ព័ន្ធ។

៤០. បើទោះជាមិនបានអានសាលក្រម ក៏វាច្បាស់ណាស់ថា សាលក្រមសំណុំរឿង ០០២/០២ មានបញ្ចូលនូវសំណុំរឿង ០០២/០១ ដោយសារតែវិសាលភាព និង ភាពស្មុគស្មាញ។ តាមរយៈការបង្ហាញជាសាមញ្ញ គ្រាន់តែនៅក្នុងជំពូកស្តីអំពីមន្ទីរសន្តិសុខ ទីតាំងសម្លាប់ និងការបោសសម្អាតផ្ទៃក្នុងគឺមានកម្រាស់រហូតដល់ ៦៦១ ទំព័រជាភាសាអង់គ្លេស ដែលទំហំនេះច្រើនជាងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ទាំងមូល។ សំណុំរឿង ០០២/០២ គ្របដណ្តប់ទៅលើអ្វីដែលអង្គជំនុំជម្រះពិពណ៌នាថាជាវិសាលភាពត្រឹមត្រូវ[33] ដែលមានការចោទប្រកាន់ចំនួន ២២ ទៅលើ នួន ជា ដោយមានទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មធំៗចំនួនប្រាំបី ក្រុមដែលជាគោលដៅចំនួន បួន និង គោលនយោបាយទាំងប្រាំ និងព្រឹត្តិការណ៍

---

បន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២" ថ្ងៃទី ២៩ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៧៤ ដល់ ៧៥។

[32] គំរោងរបស់ អវតក (វិសោធនកម្មលើទី ១៧) ថ្ងៃទី ៣០ មិថុនា ឆ្នាំ ២០១៨ (**ឯកសារភ្ជាប់ ៧**)។

[33] **E284/4/8**, 'សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ថ្ងៃទី ២៥ វិច្ឆិកា ២០១៣ កថាខណ្ឌ ៦៥, ៧០, និង ៧៦ (អំពី "តំណាងសមហេតុផល" និង អ្វីដែលជាវិសាលភាពសម្រាប់សំណុំរឿង ០០២/០២)។

ដែលត្រូវបានចោទប្រកាន់ថា បានកើតឡើងនៅទូទាំងប្រទេស នៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងយុត្តាធិការបុគ្គលរបស់ អវតក។

៤១. នៅក្នុងសំណុំរឿង ០០២/០២ មានសក្ខីកម្មសាក្សីចំនួន ១១៤ រូប, សាក្សីអ្នកជំនាញចំនួន ៨ រូប, ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ រូប, ថ្ងៃសវនាការចំនួន ២៨២ ថ្ងៃ, និងប្រតិចារិកសវនាការចំនួន ២៩ ០០០ ទំព័រ។ ប៉ុន្តែរាល់សក្ខីកម្មទាំងអស់ (និងភស្តុតាងផ្សេងៗទៀត) នៅក្នុងសំណុំរឿង ០០២/០១ ដែលថិតនៅក្នុងវិសាលភាព ០០២/០២ ហាក់ដូចជាត្រូវបានយកមកប្រើប្រាស់យ៉ាងច្រើននៅក្នុងសាលក្រម។

៤២. ស្ថិតិវិភាគបង្ហាញអំពីភាពខុសប្លែកគ្នារវាងសាលក្រមទាំងពីរ

| | **សំណុំរឿង ០០២/០១** | **សំណុំរឿង ០០២/០២** | **ទំហំធំជាងរបស់ ០០២/០២ ប្រៀបទៅនឹង ០០២/០១** |
|---|---|---|---|
| **ទំព័រសាលក្រម (អង់គ្លេស)** | ៦២៣ | ២ ២៥៩ | ៣,៦ |
| **ជើងទំព័រ (អង់គ្លេស)** | ៣ ២៩៨ | ១៤ ៤៤៦ | ៤,៧ |
| **ទំរង់នៃការទទួលខុសត្រូវ** | ៤ | ៦ | ១,៥ |
| **បទចោទ** | ៦ | ២២ | ៣,៧ |
| **ចំនួនថ្ងៃសវនាការ*** | ២២២ | ៥០៥៤ | ២.៣ |
| **ចំនួនទំព័រប្រតិចារិក** | ២៧ ០៧៧ | ៥៦ ៣២០ | ២,១ |

| | | | |
|---|---|---|---|
| (អង់គ្លេស)* | | | |
| ឯកសារ* | ៥ ៨៥៨ | ១០ ៨០៤ | ១,៨ |
| សាក្សីក្នុងសវនាការ* | ៥៨ | ១៧២ | ២,៩៧ |
| អ្នកជំនាញក្នុងសវនាការ* | ៣ | ១១ | ៣,៧ |
| ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការ | ៣១ | ៩៤ | ៣,០ |
| *បញ្ជាក់នៅពេលដែលចំនួនសរុបសំណុំរឿង ០០២/០២ ដែលថែមលើចំនួនសំណុំរឿង០០២/០១ | | | |

**៤៣.** ផ្អែកលើទិន្នន័យប្រៀបធៀបនេះ ប្រសិនបើចំនួនទំព័ររបស់សាលក្រមត្រូវបានពិចារណាជាការវាស់វែងសំខាន់បំផុតសម្រាប់ពេលវេលាត្រូវការសម្រាប់ការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រម នោះពេលវេលាដែលអង្គជំនុំជម្រះត្រូវផ្តល់ឲ្យមេធាវីការពារក្តីគឺ ១៩០ ថ្ងៃ។ ពេលវេលា ៣,៦ ដងលើសពីពេលវេលាដែលអង្គជំនុំជម្រះផ្តល់ជូនមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០១ (ដែលមានតែ ៥៣ ថ្ងៃ)។

## ២. បញ្ហាថ្មីៗដែលរកឃើញ

៤៤. អង្គជំនុំជម្រះក៏បានរកឃើញបញ្ហាថ្មីដែលបានត្រួតពិនិត្យនៅក្នុងសំណុំរឿង ដើម្បីចាត់ទុកថាជាហេតុផលល្អក្នុងការកំណត់ពេលវេលា[34]។ សាលក្រមមិនគ្រាន់តែគ្រប់ដណ្តប់លើបញ្ហា

---

[34] សំណុំF6/2 សេចក្តីសម្រេចលើពេលវេលាបន្ថែមដើម្បីដាក់បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១, កថាខណ្ឌ ៨ ដល់ ១០។

ច្បាប់ និង អង្គហេតុដែលមិនមែនជាកម្មវត្ថុនៃការពិនិត្យនៅចំពោះមុខ អវតក មានដូចជា អំពើប្រល័យពូជសាសន៍[35]នោះទេ ក៏ប៉ុន្តែថែមទាំងប្រកាសនូវបញ្ហាផ្នែកច្បាប់មួយចំនួននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឧទាហរណ៍ដូចជា ការរៀបការដោយបង្ខំ និង ការរំលោភនៅក្នុងបរិបទនៃការរៀបការដោយបង្ខំ[36]។ នេះជាបញ្ហាប្រឈមមួយសម្រាប់មេធាវីការពារក្តី ដែលចាំបាច់ត្រូវតែដកស្រង់ និង បង្កើតនូវរាល់បញ្ហាពាក់ព័ន្ធ ដើម្បីដាក់ជូនអង្គជំនុំជម្រះ។ អាស្រ័យហេតុនេះហើយ វានឹងជាយុត្តិកម្មមួយសម្រាប់ការបន្ថែមចំនួនទំព័រ និង ពេលវេលាសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា។

## ៣. ប្រៀបធៀបជាមួយការអនុវត្តនៅតុលាការព្រហ្មទណ្ឌផ្សេងទៀត

៤៥. ដូចអង្គជំនុំជម្រះនេះដែរ អង្គជំនុំជម្រះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ជាញឹកញាប់ខ្លួនបានទទួលស្គាល់អំពីចំនួនទំព័រ និង ភាពស្មុគស្មាញនៃសាលក្រម ទំហំនៃសំណុំរឿង និង បញ្ហាថ្មីៗដែលបានពិនិត្យថា ជា"មូលហេតុសមស្រប"[37] ដើម្បីបន្ថែមពេលវេលាដែលបានកំណត់។ ឧទារហណ៍នៅក្នុងសំណុំរឿង *Mladić* ចៅក្រមនៅអង្គបុរេជំនុំជម្រះ

---

[35] **E465** "សាលក្រមសំណុំរឿង ០០២/០២" ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ផ្នែក ១៣.២.១០.១០ និង ១៣.៣.១០.៥។

[36] **E465** "សាលក្រមសំណុំរឿង ០០២/០២" ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ផ្នែក ១៤.៤។ មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួនតូចដែលពិនិត្យលើបញ្ហានេះ។ *Prosecutor v. Brima et al.*, SCSL-2004-16-A, 'សាលក្រម', ថ្ងៃទី ២២ កុម្ភៈ ២០០៨; *Prosecutor v. Sesay et al.*, SCSL-04-15-A, 'សាលក្រម', ថ្ងៃទី ២៦ តុលា ២០០៩; *Prosecutor v. Katanga and Ngudjolo Chui*, ICC-01/04-01/07-717, 'សេចក្តីសម្រេចលើការបញ្ជាក់ការចោទប្រកាន់', ថ្ងៃទី ៣០ កញ្ញា ២០០៨ (ការរៀបការដោយបង្ខំ និង រំលោភ នៅក្នុងបរិបទការរៀបការដោយបង្ខំ ត្រូវបានចែងនៅក្នុងបទល្មើសទាសករផ្លូវភេទ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម; *Prosecutor v. Ongwen*, ICC-02/04-01/15-422-Red, 'សេចក្តីសម្រេចលើការបញ្ជាក់ពីបទចោទប្រឆាំងនឹង Dominic Ongwen', ថ្ងៃទី ២៣ មីនា ២០១៦; *Prosecutor v. Al Hassan,* ICC-01/12-01/18-2-tENG, 'ដីកាឃុំខ្លួន Al Hassan Ag Abdoul Aziz Ag Mohamed Ag Mahmoud', ថ្ងៃទី ២៧ មីនា ២០១៨ (ចំណាត់ថ្នាក់ឡើងវិញនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៨)។

[37] វិធាន ១២៧ (ក) (១) នៃវិធាន ICTY និង វិធាន ១១៦ (ក) នៃវិធាន ICTY។

បានពិចារណាទៅលើ "ចំនួនទំព័រ និង ភាពស្មុគ្រស្មាញនៃសំណុំរឿង" ហើយបានផ្តល់ជូនភាគីដាក់ជូនសេចក្តីជូនដំណឹងរបស់ខ្លួនក្នុងរយៈពេល ១២០ ថ្ងៃ នៅបន្ទាប់ពីសាលក្រមបានចេញ[38]។ នៅក្នុងសំណុំរឿង *Karadžić* ចៅក្រមអង្គបុរេជំនុំជម្រះបានពិចារណាដល់ចំនួនទំព័រ ភាពស្មុគ្រស្មាញនៃសំណុំរឿង និង ឋានៈខ្ពស់របស់ជនជាប់ចោទ និង ធនធានដែលផ្តល់ជូនដល់មេធាវីការពារក្តី[39] ក្នុងការសម្រេចផ្តល់ជូនដល់ភាគីនូវពេលវេលាបន្ថែម ៩០ ថ្ងៃ ក្នុងការដាក់ជូនសេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ ដោយភាគីទាំងអស់មានរយៈពេលរហូតដល់ ១២០ ថ្ងៃ[40]។ ការបន្ថែមពេលវេលាដូចគ្នានេះដែរ (មុនដំបូង ៩០ ថ្ងៃ និង ជារឿយៗ ៦០ ថ្ងៃ) ត្រូវបានផ្តល់ឱ្យដើម្បីដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង *Popović et al.*,[41] *Sainović et al.*[42] និង *Nyiramasuhuko et al.*[43]។

៤៦. ពេលដែលសាលក្រម ០០២/០២ អាចប្រៀបធៀបបានទៅនឹងសំណុំរឿងទាំងនេះទៅលើភាពស្មុគ្រស្មាញ វាក៏បង្ហាញឱ្យឃើញដាច់ពីគ្នាផងដែរពីសំណុំរឿងទាំងនេះ ដែលត្រូវការពេលវេលា និង ចំនួនទំព័របន្ថែមច្រើនជាងនេះបន្ថែមទៀត សម្រាប់ការដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ ខុសគ្នាពីសំណុំរឿង *Mladić* និង *Karadžić* ដោយសារសំណុំរឿង នួន ជា បានពិនិត្យបទចោទច្រើនជាងពីរដង និងគ្របដណ្តប់មិនគ្រាន់តែលើ

---

[38] សេចក្តីសម្រេច *Mladić* ទំព័រ ២។

[39] សេចក្តីសម្រេចលើកទី ១ *Karadžić* ទំព័រ ៣។ សេចក្តីសម្រេចលើកទី ១ *Karadžić* ទំព័រ ៣

[40] សេចក្តីសម្រេច *Karadžić* ទំព័រ ១។ សេចក្តីសម្រេចលើកទី ២ *Karadžić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានផ្តល់ពេលវេលាបន្ថែម ៦០ ថ្ងៃ និង បន្ទាប់មកផ្តល់ ៣០ ថ្ងៃបន្ថែមទៀត ដោយសារតែមានការយឺតយ៉ាវផ្នែកថវិកាសម្រាប់មេធាវីការពារក្តី។

[41] សេចក្តីសម្រេច *Popović,* ទំព័រ ២។

[42] សេចក្តីសម្រេច *Sainović*, ទំព័រ ៣។

[43] *Nyiramasuhuko et al. v. Prosecutor,* ICTR-98-42-A "សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមសម្រាប់ដាក់ជូននូវបណ្តឹងសាទុក្ខ" ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ៩។

ទីតាំងកើតហេតុប៉ុណ្ណោះទេ តែថែមទាំងគ្របដណ្តប់ដល់ទីតាំងដែលមិនបានបញ្ជាក់ច្បាស់លាស់ផងដែរ។ នៅក្នុងសំណុំរឿង *Mladić* និង *Karadžić* ដីការចោទប្រកាន់បញ្ជាក់ពេលវេលា (រហូតដល់កាលបរិច្ឆេទពិតប្រាកដ), ទីតាំង, ចំនួនជនរងគ្រោះ, និង បញ្ហាលម្អិតផ្សេងទៀតទាក់ទងនឹងឧក្រិដ្ឋកម្មនិមួយៗ ដែលត្រូវបានស្គាល់ថាជា "កាលវិភាគនៃហេតុការណ៍" (ហេតុការណ៍រាយក្នុងកាលវិភាគមួយចំនួន ដែលភ្ជាប់ទៅនឹងដីការបញ្ជូនរឿងទៅជំនុំជម្រះ)។ ម្យ៉ាយវិញទៀត ដីការដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ចោទប្រកាន់ដោយមិនច្បាស់លាស់ ដូចជាថា "មនុស្សជាច្រើន" ត្រូវបានសម្លាប់នៅក្នុងប្រទេស ឬ ក៏ថា បានបាត់ខ្លួនពីតំបន់នៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ វាពិតជាមានការលំបាក និង ស្មុគ្រស្មាញជាងនេះទៅទៀតក្នុងការរៀបចំការពារក្តីដែលមានគោលបំណងជាក់លាក់ និង មានប្រសិទ្ធិភាព ដើម្បីតទល់ទៅនឹងការចោទប្រកាន់មិនច្បាស់លាស់។ អាស្រ័យហេតុនេះហើយមេធាវីការពារក្តីត្រូវការពេលវេលាបន្ថែម ដើម្បីលើកអង្គហេតុដែលគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងត្រូវការចំនួនទំព័របន្ថែមដើម្បីបង្ហាញពីមូលដ្ឋានរបស់ខ្លួនជំទាស់ទៅនឹងសាលក្រម។ សម្រាប់ហេតុផលនេះ បើទោះជាអង្គជំនុំជម្រះអនុវត្តតាមការសម្រេចលើពេលវេលាបន្ថែម ដែលតុលាការព្រហ្មទណ្ឌផ្សេងទៀត ជាជាងរបៀបដែលខ្លួនសម្រេចនៅក្នុងសំណុំរឿង ០០២/០១ នោះរយៈពេល ១២០ ថ្ងៃដែលផ្តល់ជូន *Mladić* និង *Karadžić* នៅតែមិនគ្រប់គ្រាន់នៅក្នុងសំណុំរឿងនេះទេ។

៤៧. ជាងនេះទៀតនោះ សំណុំរឿង *Popović et al.*, *Sainović et al.* និង *Nyiramasuhuko et al.* មានសាលក្រម និង ឯកសារសំណុំរឿងតូចជាងសំណុំរឿង ០០២/០២ ទៅទៀត និងមានជនជាប់ចោទជាច្រើន។ ឧទាហរណ៍ សាលក្រមសាលាដំបូងសំណុំរឿង *Popović et al* មានកម្រាស់ ៨៣២ ទំព័រ និងមានបុគ្គល ៧ រូប។ សំណុំរឿង *Sainović et al.* សាលក្រមសាលាដំបូងមានកម្រាស់ ១ ៤៣៥ ទំព័រ និង មានបុគ្គលប្រាំមួយរូប។ និងសាលក្រមសំណុំរឿង *Nyiramasuhuko et al.* មាន ១ ៤៦៩ ទំព័រ ហើយមានបុគ្គលប្រាំមួយរូប។ តែផ្ទុយទៅវិញ ស្ទើរតែ ២ ២៥៩ ទំព័ររបស់សាលក្រមគឺមានភាពពាក់ព័ន្ធដោយផ្ទាល់ជាមួយ

នួន ជា។ គួរកត់សំគាល់ផងដែរថា អង្គជំនុំជម្រះបានបរិយាយនៅក្នុងសាលក្រមរបស់ខ្លួនថា "ជាអ្នកធ្វើការសម្រេច" ទៅលើអជ្ញាធរ និង គ្រប់គ្រង ជាមួយ ប៉ុល ពត[44]។ ផ្នែកដែលពាក់ព័ន្ធយ៉ាងច្រើនទៅនឹង នួន ជា ដោយប្រៀបធៀបទៅនឹងជនជាប់ចោទផ្សេងទៀតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាយុត្តិកម្ម គួរតែត្រូវបានផ្តល់ពេលវេលាបន្ថែមជូនមេធាវីការពារក្តីក្នុងការរៀបចំ និង ដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា។

## ខ. មិនមានបណ្តឹងសាទុក្ខរបៀបនៅចំពោះមុខ អវតក

៤៨. បន្ថែមពីលើការកំណត់អំពីកំហុសនៅក្នុងសាលក្រម សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវតែមានសេចក្តីសម្រេច ដែលបានសម្រេចនៅអំឡុងពេលសវនាការ ដែលមិនមែនជាកម្មវត្ថុ នៃបណ្តឹងសាទុក្ខភ្លាមៗ។ បណ្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចដូចនេះ "ត្រូវតែជាបន្ទុកធ្ងន់ធ្ងរសម្រាប់ដើមបណ្តឹង ហេតុដូចនេះហើយខ្លួនត្រូវតែរាប់បញ្ចូលនូវមូលដ្ឋាន មួយ ឬ ច្រើន [...] នៃបណ្តឹងសាទុក្ខដែលអាចកើតមានឡើងនៅក្នុងសាលក្រម"[45]។

៤៩. នៅក្នុងអំឡុងពេលនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចយ៉ាងច្រើន ដែលក្នុងចំណោមនោះ មេធាវីការពារក្តីអាចកំណត់ថាយ៉ាងហោចណាស់សេចក្តីសម្រេចចំនួន ៥៦ ដែលអាចមានកំហុស។ បន្ថែមលើសេចក្តីសម្រេចផ្ទាល់មាត់ដែលចេញជាញឹកញាប់។ វានឹងត្រូវការពេលវេលាច្រើនសម្រាប់មេធាវីការពារក្តីក្នុងការពិនិត្យមើលផលប៉ះពាល់មកលើ នួន ជា ដែលអាចមាននៅក្នុងសាលក្រម និង ដើម្បីពិនិត្យមើលថា តើខ្លួនអាចរកឃើញដោយសមរម្យនៃមូលដ្ឋានដែលអាចប្តឹងសាទុក្ខដែលកើតចេញពីសាលក្រម។

---

[44] សូមមើល សាលក្រម កថាខណ្ឌ ៥៦១, ៣៨៨៨, ៤០៨០, ៤១០៧, ៤១១០, ៤១២៧, ៤១៥៨, ៤១៧១, ៤១៨៧, ៤១៩៦, និង ៤៣៧៧។

[45] **F9** "សេចក្តីសម្រេចលើកទីពីរ លើការកំណត់ពេលវេលា និង ចំនួនទំព័រក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១៦។

**គ. មេធាវីការពារក្តីបានប្រឈមនឹងបញ្ហាធនធាន នៅបន្ទាប់ពីចេញសាលក្រមសង្ខេប**

៥០. បើទោះជាប្រសិនបើសាលក្រមសង្ខេបអាចជាមូលដ្ឋានគ្រប់គ្រាន់ ដែលមេធាវីការពារក្តីអាចរៀបចំបណ្តឹងសាទុក្ខរបស់ខ្លួនក៏ដោយ តែខ្លួនមិនបានធ្វើការវិភាគដោយមានប្រសិទ្ធភាពនោះទេ ដោយសារតែខ្លួនបានប្រឈមទៅនឹងបញ្ហាធនធានជាច្រើននៅក្នុងពេលប៉ុន្មានខែចុងក្រោយនេះ។ នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រយៈពេលតិចជាងពីរសប្តាហ៍ នៅបន្ទាប់ពីការប្រកាសសាលក្រមសង្ខេប សហមេធាវីអន្តរជាតិក្នុងពេលបច្ចុប្បន្ននេះ (នៅពេលនោះជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់) បានលាលែងពីតំណែង ដូចគ្នានឹងទីប្រឹក្សាច្បាប់ម្នាក់ទៀតដែរ។ នៅបន្ទាប់មក អតីតសហមេធាវីការពារក្តីអន្តរជាតិ ត្រូវបានបញ្ចប់ការងារនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨ ដោយមិនបានបំពេញនូវការផ្ទេរការងារ ដោយនៅសល់តែអ្នកវិភាគភស្តុតាងថ្នាក់ខ្ពស់មួយរូបនៅក្នុងក្រុមគាំទ្រផ្នែកច្បាប់។

៥១. សហមេធាវីការពារក្តីអន្តរជាតិក្នុងពេលបច្ចុប្បន្នទើបតែត្រូវបានចាត់តាំងនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩[46] ហើយបានចូលរួមក្នុងក្រុមក្នុងតួនាទីជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់នៅបន្ទាប់ពីសវនាការសំណុំរឿង ០០២/០១ បានបញ្ចប់។ ក្រុមគាំទ្រផ្នែកច្បាប់ទាំងមូលទើបតែដំណើរការចាប់តាំងពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០១៩។ ទីប្រឹក្សាជាន់ខ្ពស់បីរូបកំពុងតែធ្វើការមិនពេញម៉ោង។ មានតែសមាជិកពីររូបនៅក្នុងចំណោម សមាជិកទាំងប្រាំពីររូបដែលមានវត្តមាននៅពេលប្រកាសសាលក្រមសង្ខេប។ ទីប្រឹក្សាថ្មីពីររូបមិនសូវយល់ពីសំណុំរឿងច្រើនប៉ុន្មានទេដោយសារតែគាត់មិនធ្លាប់ធ្វើការនៅ អវតក ហើយចំណែកឯទីប្រឹក្សាជាន់ខ្ពស់ពីររូប មកចូលរួមក្នុងក្រុមវិញនៅបន្ទាប់ពីឈប់អស់រយៈពេលជាងមួយឆ្នាំកន្លះ[47]

---

[46] **E464** ការចាត់តាំងមេធាវីបរទេសថ្មី។

[47] នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការចាត់តាំងមេធាវីថ្មី ដោយអមជាមួយនឹងកត្តាផ្សេងទៀត ថាជាមូលហេតុត្រឹមត្រូវក្នុងការផ្តល់ជូននូវពេលវេលាបន្ថែម សម្រាប់ការដាក់ជូននូវបណ្តឹងសាទុក្ខ។ សូម **សំណើបន្ទាន់លើកទីមួយរបស់ ឌុច ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូន** ទំព័រ ២៦ នៃ ៣១ **ដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២**

ហើយទីប្រឹក្សាច្បាប់ទីបី បានចូលរួមក្នុងក្រុមនៅបន្ទាប់ពីការបញ្ចប់កម្មសិក្សារបស់ខ្លួននៅក្នុងក្រុមមេធាវីការពារក្ដីនៅជាងពីរឆ្នាំមុន។

៥២. ដោយសារតែបញ្ហាប្រឈមនឹងធនធាននេះហើយ នៅបន្ទាប់ពីថ្ងៃចាត់តាំងសហមេធាវីអន្តរជាតិនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩ សហមេធាវីការពារក្ដីបានចំណាយពេលយ៉ាងច្រើនទៅលើការងាររដ្ឋបាលដើម្បីជ្រើសរើសសមាជិកបន្ថែម ការណែនាំក្នុងក្រុម និង ការបង្កើតប្រព័ន្ធធ្វើការ និង លំហូរការងារនៅក្នុងក្រុម។ ប្រការនេះបានធ្វើឱ្យខ្លួនមានពេលវេលាតិចតួចណាស់សម្រាប់ការរៀបចំបណ្ដឹងសាទុក្ខ ឬ ក៏ពិនិត្យឡើងវិញពីសំណុំរឿង និង យុត្តិសាស្ត្ររបស់ខ្លួនឱ្យបានទូលំទូលាយបន្ថែមទៀត ដោយសារតែការដឹកនាំរបស់មេធាវីថ្មី។

៥៣. បន្ថែមពីលើនេះ មេធាវីការពារក្ដីគួរតែគត់សម្គាល់ផងដែរថា ប្រធានអង្គភាពគាំពារការការពារក្ដីបានចាកចេញពី អវតក នៅថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០១៩។ នៅក្នុងដំណាក់កាលនេះ មេធាវីការពារក្ដីបានត្រឹមតែទទួលដំណឹងថា ការិយាល័យរដ្ឋបាល អវតក កំពុងតែរកអ្នកមកជំនួសតំណែងនេះ។ មេធាវីការពារក្ដីមិនទាន់ត្រូវបានជូនដំណឹងអំពីវិធានការបណ្ដោះអាសន្ននៅក្នុងការសម្រេច និង ការណែនាំទៅលើតម្រូវការផ្នែករដ្ឋបាល នៅក្នុងអំឡុងពេលជ្រើសរើសនេះទេ។ ប្រសិនបើបញ្ហានេះមិនត្រូវបានណែនាំឱ្យទាន់ពេល និង ដោយប្រសិទ្ធភាព នោះបញ្ហារដ្ឋបាលនេះអាចបង្កើតឱ្យមានការយឺតយ៉ាវបន្ថែមទៀត ឬ ធ្វើឱ្យប៉ះពាល់ដល់ការងារជាសារធាតុរបស់មេធាវីការពារក្ដី។

៥៤. ការប្រឈមទៅលើធនធាន ដែលលើកឡើងនេះគឺជាយុត្តិកម្មមួយ ដើម្បីពន្យារពេលនៃការដាក់ជូននូវសេចក្ដីជូនបណ្ដឹងអំពីបណ្ដឹងសាទុក្ខ ដើម្បីគោរពសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់សម្រាប់ការពារក្ដី។ ការពន្យារពេលនេះអាចអនុញ្ញាតឱ្យសមាជិកទាំងអស់យល់ ឬ ក៏ស្វែងយល់ឡើងវិញពីសំណុំរឿង និង កំណត់យកនូវយុត្តិសាស្ត្រការពារក្ដី និង ការអនុវត្តរបៀបធ្វើការងារថ្មី ដើម្បីរៀបចំបណ្ដឹងសាទុក្ខរបស់

---

មើល F6/2 សេចក្ដីសម្រេចលើពេលវេលាបន្ថែមដើម្បីដាក់ជូនបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១" កថាខណ្ឌ ៨ និង ១០។

នួន ជា។ មេធាវីការពារក្ដីសូមបញ្ជាក់ថា ការពន្យារពេលបែបនេះត្រូវបានពិចារណាថា ជាការបំពេញបន្ថែមទៅនឹងការពន្យារពេលនានា ដែលអង្គជំនុំជម្រះអាចនឹងផ្ដល់ជូនដោយសារតែអំណះអំណាងនៅក្នុងសំណើនេះ។

## ឃ. កត្តាមិនពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ

៩៥. គួរបញ្ជាក់ផងដែរថា មានកត្តាមួយចំនួន ដែលមិនពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដោយគិតអំពីសំណើនេះ។ បញ្ហាទីមួយនោះគឺ ថវិការ។ តាមពិតទៅ តាមពាក្យរបស់ អវតក ខ្លួនឯងផ្ទាល់លើកឡើងថា "ដំណើរការដ៏មានប្រសិទ្ធភាពរបស់ [អវតក] កន្លងមកត្រូវបានរំខានដោយរឿងខ្វះខាតថវិការ"[48] ដែលអង្គជំនុំជម្រះនេះបានសម្រេចដ៏ត្រឹមត្រូវកាលពីមុនមកថា៖

> ដោយហេតុថា ចៅក្រមនៅគ្រប់ពេលទាំងអស់ ជាក់ច្បាស់ណាស់ ត្រូវមានកាតព្វកិច្ចពិចារណាលើប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ដូច្នេះចៅក្រម ជានិច្ចកាលត្រូវអនុវត្តទៅតាមវិសាលភាពនៃច្បាប់ ដែលជាគោលការណ៍ ដែលមានលក្ខណៈសំខាន់ជាងការសន្សំសំចៃផ្នែកថវិការ។ [...] ប្រសិនបើពុំមានថវិការគ្រប់គ្រាន់ក្នុងការធានានូវការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ។ ដើម្បីរាំងខ្ទប់បញ្ហានេះ កិច្ចដំណើរការនីតិវិធីត្រូវបន្ត ដោយពុំមានសេចក្ដីសម្រេចណាមួយលើអង្គច្បាប់ និងអង្គហេតុ ត្រូវទទួលរងនូវឥទ្ធិពលដោយឥតសមស្របពីបញ្ហាហិរញ្ញវត្ថុឡើយ[49]។

---

[48] គំរោងរបស់ អវតក (វិសោធនកម្មលើទី ១៩) ថ្ងៃទី ៣១ ធ្នូ ឆ្នាំ ២០១៨ កថាខណ្ឌ ១៣ (**ឯកសារភ្ជាប់ ៨**)។

[49] E284/4/8, 'សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ថ្ងៃទី ២៥ វិច្ឆិកា ២០១៣ កថាខណ្ឌ ៧៥។

៥៦. សេចក្តីសន្និដ្ឋាននៅក្នុងបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០២/០១ មិនគួរត្រូវបានគិតទៅក្នុងសេចក្តីសម្រេចបន្ថែមចំនួនទំព័រ និង ពេលវេលានៅក្នុងសំណុំរឿងនេះទេ។ នៅបន្ទាប់ពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះបានសម្រេចថា "បើទោះបី ភស្តុតាងនៅតែមានលក្ខណៈដូចគ្នាជាផ្លូវការទៅនឹងសំណុំរឿងដែលបានបំបែកក៏ដោយ ក៏ភាពរួមគ្នានេះមិនបានពន្លាតដល់ការយល់ឃើញ ហើយធាតុរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ក្នុងសំណុំរឿង ០០២ **ត្រូវបង្ហាញជាថ្មី**"[50]។ គោលជំហរត្រូវតែប្រកាន់យកដូចគ្នា គឺមានន័យថា អង្គជំនុំជម្រះមិនត្រូវទាញយកការរកឃើញពីបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ មកក្នុងសំណុំរឿង ០០២/០២ នោះទេ ហើយក៏មិនត្រូវប្រើប្រាស់ការរកឃើញទាំងនេះមកបដិសេធសំណើសុំនេះទេ។

៥៧. ជាងនេះទៅទៀតនោះ ការចេញសាលក្រមសង្ខេប មិនគួរមានការរារាំងដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើសំណើនេះនោះទេ។ សាលក្រមសង្ខេបមានចំនួន ៣១ ទំព័រ ដោយមិនមានជើងទំព័រ, ឯកសារ, សក្ខីកម្មរបស់សាក្សី ដែលយកមកគាំទ្រដល់សេចក្តីសម្រេចរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូង តាមរយៈការទទួលស្គាល់របស់ខ្លួនយល់ឃើញថា វាមិនមានអនុភាពតាមផ្លូវច្បាប់នោះទេ តែ"សំអាងហេតុដែលមានអនុភាពតាមផ្លូវច្បាប់ គឺជាសំអាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសាលក្រម ដែលអង្គជំនុំជម្រះនឹងចេញ [...] នៅក្នុងពេលសមស្របខាងមុខ"[51]។ តែផ្ទុយទៅវិញសាលក្រមសង្ខេបគឺ ច្បាស់ណាស់គឺដើម្បីជម្រាបជូនសាធារណៈជនទូទៅអំពីលទ្ធផលការងាររបស់អង្គជំនុំជម្រះសាលាដំបូង ជាជាងជម្រាបជូនដល់មេធាវីការពារក្តីទៅលើបទចោទនានា។ អាស្រ័យហេតុនេះហើយវាមិនអាចចាត់ទុកជាមូលដ្ឋានសម្រាប់ការ

---

[50] **E301/9/1/1/3** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២" ថ្ងៃទី ២៩ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៨៥ (បញ្ជាក់បន្ថែម)។

[51] "សាលក្រមសង្ខេបសំណុំរឿង ០០២/០២" ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

រៀបចំរបស់មេធាវីការពារក្ដីសម្រាប់បណ្ដឹងសាទុក្ខ នៅមុនពេលដែលសាលក្រមពេញលេញចេញនៅថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៩ ឬ ជាមូលដ្ឋានក្នុងការកំណត់ចំនួនទំព័រ និងពេលវេលាបន្ថែមត្រូវបានផ្ដល់ជូនដល់មេធាវីការពារក្ដីរៀបចំបណ្ដឹងសាទុក្ខរបស់ខ្លួននោះទេ។

**ផ្នែកទី ៥. សេចក្ដីសន្និដ្ឋាន**

៥៨. មេធាវីការពារក្ដីយល់ឃើញថា នៅក្នុងដំណាក់កាលដំបូងនេះ ដោយមិនមានឱកាសពិនិត្យឱ្យបានត្រឹមត្រូវនៃសាលក្រម ខ្លួនគិតថា ការបន្ថែមចំនួន ១៥០ ថ្ងៃ (ពេលវេលាទាំងអស់ ១៥០ ថ្ងៃ) គឺជាចំនួនពេលវេលាតិចបំផុត ត្រឹមត្រូវ និង សមហេតុផលដើម្បីរៀបចំ និងដាក់ជូនសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា។ តាមពិតទៅ ប្រសិនបើអង្គជំនុំជម្រះ អនុវត្តតាមអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ នោះការបន្ថែម ១៦០ ថ្ងៃ (សរុបទាំងអស់ ១៩០ ថ្ងៃ) នឹងគ្រប់គ្រាន់។

៥៩. មេធាវីការពារក្ដីពិចារណាឃើញទៀតថា ការបន្ថែមទំព័រចំនួន ៧០ (ចំនួនសរុបទាំងអស់ ១០០ ទំព័រ) គឺចាំបាច់ដើម្បីអនុញ្ញាតឱ្យមានទំហំមួយដើម្បីរាប់បញ្ចូលនូវបញ្ហាទាំងអស់ដែលខ្លួនមានបំណងប្ដឹង។ មេធាវីការពារក្ដីបញ្ជាក់ម្ដងទៀតថា ខ្លួននឹងជូនដំណឹងទៅអង្គជំនុំជម្រះភ្លាមៗនៅបន្ទាប់ពីការកំណត់ចំនួនទំព័រ ឬ ពេលវេលា ប៉ុន្មានដែលត្រូវការដើម្បីបញ្ចប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។

៦០. សម្រាប់ហេតុផលស្រដៀងគ្នានេះដែរ មេធាវីការពារក្ដីរំពឹងថា ការបន្ថែមចំនួនទំព័រ និងពេលវេលាសមហេតុផលមួយ នឹងមានសារប្រយោជន៍ផងដែរ សម្រាប់ការដាក់ជូននូវបណ្ដឹងសាទុក្ខ។ តែទោះជាយ៉ាងណាក៏ដោយ ដោយពិចារណាទៅលើយោបល់របស់អង្គជំនុំជម្រះថា វាជាការឆាប់រហ័សពេកក្នុងពេលនេះក្នុងការកំណត់ថា ចំនួនទំព័រ និងពេលវេលាប៉ុន្មានសម្រាប់បណ្ដឹងសាទុក្ខនោះ[52]។ មេធាវីការពារក្ដីនឹងដាក់សំណើរនេះមួយ

---

[52] F3/3 "សំណើលើកទីមួយលើការកំណត់ពេលវេលា និង ទំព័រ នៅក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១០។

ទៀតនៅបន្ទាប់ពីដាក់ជូនសេចក្តីជូនដំណឹង។ ដូចគ្នានេះដែរ បើទោះជាសំណើសុំធនធានបន្ថែមអាចចាំបាច់ដើម្បីត្រូវការជំនួយបន្ថែម ឬ ក៏ពេលវេលាបន្ថែមក៏ដោយ តែមេធាវីការពារក្តី មិនទាន់គិតទៅដល់រឿងនេះក្នុងពេលនេះទេ ប៉ុន្តែអាចនឹងដាក់ជូននូវសំណើក្នុងបញ្ហានេះនៅពេលក្រោយក្នុងអំឡុងពេលដំណើការបណ្តឹងសាទុក្ខ។

**ផ្នែកទី ៦. សំណើសុំ**

៦១. សម្រាប់ហេតុផលទាំងអស់នេះ មេធាវីការពារក្តីសូមស្នើជាបន្ទាន់ដល់អង្គជំនុំជម្រះតុលាការកំពូល៖

(ក) ចំនួនពេលវេលា ១៥០ ថ្ងៃបន្ថែម (សរុបទាំងអស់ ១៨០ ថ្ងៃ) និង

(ខ) ចំនួន ៧០ ទំព័របន្ថែម (សរុបទាំងអស់ ១០០ ទំព័រ ជាភាសាអង់គ្លេស)

ដើម្បីរៀបចំ និង ដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់នឹងសាលក្រម។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Doreen CHEN